ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

**ធនាគារជាតិ នៃ កម្ពុជា**

លេខ ធ៧.០៥.០៤៥ ប្រក

# ប្រកាស

## ស្តីពី

## គោលនយោបាយឥណទាន នីតិវិធី និងសិទ្ធអំណាចផ្តល់ឥណទាន

## ទេសាភិបាលធនាគារជាតិនៃកម្ពុជា

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/២៧ ចុះថ្ងៃទី២៦ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តិទៅនៃធនាគារជាតិនៃកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/១១៩៩/១៣ ចុះថ្ងៃទី១៨ ខែវិច្ឆិកា ឆ្នាំ១៩៩៩ ដែលប្រកាសអោយប្រើច្បាប់ស្តីពីគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៤/២៤៤ ចុះថ្ងៃទី ០៧ ខែកញ្ញា ឆ្នាំ២០០៤ ស្តីពីការតែងតាំង **ឯកឧត្តម ជា ចាន់តូ** ជាអគ្គទេសាភិបាលធនាគារជាតិនៃកម្ពុជា
- យោងតាមស្មារតីនៃអង្គប្រជុំថ្នាក់ដឹកនាំធនាគារជាតិនៃកម្ពុជាថ្ងៃទី ០៤ ខែមិនា ឆ្នាំ ២០០៥

## សំរេច

### ប្រការ ១.-

រាល់គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ ត្រូវអនុវត្តអោយបានស្របតាមគោលនយោបាយឥណទានត្រឹមត្រូវនិងប្រុងប្រយ័ត្ន ការប្រតិបត្តិជាទូទៅនិងនីតិវិធីក្នុងការផ្តល់ឥណទានដែលត្រូវតែបានអនុម័តនិងពិនិត្យឡើងវិញដោយត្រឹមត្រូវពីគណៈគ្រប់គ្រង និង/ឬក្រុមប្រឹក្សាភិបាល ។

### ប្រការ ២.-

រាល់គ្រឹះស្ថានធនាគារ និងហិរញ្ញវត្ថុត្រូវបង្កើត :

១- គោលនយោបាយនិងនីតិវិធីជាលាយល័ក្សអក្សរសំរាប់ដាក់ចេញនូវគោលនយោបាយឥណទាន នីតិវិធីនិងកំណត់សិទ្ធអំណាចអោយខ្ចីរបស់មន្ត្រីឥណទាន និង/ឬគណៈ

កម្មការឥណទាន និងក្រុមប្រឹក្សាភិបាល ហើយគោលនយោបាយនិងនីតិវិធីទាំងនោះត្រូវតែបានបញ្ជូនទៅគ្រប់បុគ្គលិក ដែលពាក់ព័ន្ធនឹងសកម្មភាពផ្តល់ឥណទាន ។

២- សំណុំឯកសារឥណទានរបស់អ្នកសុំខ្ចីទាំងអស់ត្រូវតែមានព័ត៌មានថ្មីៗគ្រប់គ្រាន់ និងអាចជឿទុកចិត្តបាន ដូចមានក្នុងឧបសម្ព័ន្ធភ្ជាប់ជាមួយនេះ ។

**ប្រការ ៣.-**

គោលនយោបាយឥណទាន នីតិវិធីនិងសិទ្ធអំណាចអោយខ្ចីត្រូវមាន ការវិភាគឥណទាន ដំណើរការអនុម័តឥណទាន នីតិវិធីពិនិត្យឥណទានឡើងវិញតាមគ្រា កំរិតកំណត់អនុម័តឥណទានរបស់មន្ត្រី និង/ឬ គណៈកម្មការឥណទាន វត្ថុធានា និងពត៌មានចាំបាច់ផ្សេងៗទៀត ។

**ប្រការ ៤.-**

អគ្គនាយកដ្ឋាន អគ្គលេខាធិការដ្ឋាន អគ្គាធិការដ្ឋាន អគ្គបេឡា គ្រប់នាយកដ្ឋាន អង្គភាព គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុនៅក្រោមឱវាទ និងក្រោមអាណាព្យាបាលធនាគារជាតិនៃកម្ពុជាត្រូវអនុវត្តម៉ឺងម៉ាត់នូវប្រកាសនេះ តាមភារកិច្ចរៀងៗខ្លួន ។

**ប្រការ ៥.-**

ប្រកាសនេះមានប្រសិទ្ធភាពអនុវត្តចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី ១០ ខែ មិនា ឆ្នាំ ២០០៥

**ទេសាភិបាល**

**ជា-ចាន់តូ**

**កន្លែងទទួល**

- ដូចប្រការ៤ "ដើម្បីអនុវត្ត"
- កាលប្បវត្តិ
- ឯកសារ

**ចម្លងជូន**

- សមាជិកក្រុមប្រឹក្សាភិបាល
- ទីស្តីការគណៈរដ្ឋមន្ត្រី "ដើម្បីជ្រាបជាពត៌មាន"
- នាយកដ្ឋានរដ្ឋបាលនៃទីស្តីការគណៈរដ្ឋមន្ត្រី "ដើម្បីចុះក្នុងរាជកិច្ច"

**ឧបសម្ព័ន្ធៈ**

ប្រកាសលេខ ធ៧.០៥-០៥៤ប្រក

ចុះថ្ងៃទី ១០ ខែ មិនា ឆ្នាំ២០០៥

## ព័ត៌មានដែលត្រូវរក្សាទុកក្នុងសំណុំឯកសារឥណទាន

### I ព័ត៌មានអំពីអ្នកសុំខ្ចី

ក- រូបវន្តបុគ្គល ÷ អាស័យដ្ឋាន អាស័យដ្ឋានទំនាក់ទំនង មុខរបរ និយោជក ប្រវត្តិ និងឬ ចំណូល ស្ថានភាពហិរញ្ញវត្ថុ និងឬ មូលនិធិផ្ទាល់សុទ្ធ និងព័ត៌មានពាក់ព័ន្ធផ្សេងទៀត ។

ខ- និតិបុគ្គល ÷ លក្ខន្តិកៈក្រុមហ៊ុន ឯកកម្មសិទ្ធិ ឬ សហកម្មសិទ្ធិ ប្រវត្តិ និងសាវតាអាជីវកម្ម រចនាសម្ព័ន្ធចាត់តាំងក្រុមហ៊ុន គណៈគ្រប់គ្រង នាយក ភាគទុនិក ម្ចាស់កម្មសិទ្ធិ សហកម្មសិទ្ធិ ស្ថានភាពហិរញ្ញវត្ថុ និងលទ្ធផល និងព័ត៌មានពាក់ព័ន្ធផ្សេងទៀត ។

### II ព័ត៌មានអំពីការផ្តល់ឥណទាន

ក- ពិពណ៌នាពីប្រភេទឥណទាន (ឥណទានវិបារូបនី ឥណទានបង្វិលជុំ ឥណទានសងរំលោះ ចំនួនប្រាក់ ប្រភេទរូបិយប័ណ្ណ)

ខ- គោលបំណងឥណទាន

គ- លក្ខខ័ណ្ឌឥណទាន ÷ កំរិតកំណត់ អត្រាការប្រាក់ តារាងពេលវេលាសងប្រាក់ រយៈពេល កាលកំណត់ និងកាលបរិច្ឆេទផុតកំណត់

ឃ- វត្ថុធានា ÷ លេខប័ណ្ណកម្មសិទ្ធិវត្ថុធានា ទីតាំង ប្រភេទ ចំនួនប្រាក់ដែលបានវាយតំលៃ កាលបរិច្ឆេទនិងទីកន្លែងវាយតំលៃ ឈ្មោះអ្នកវាយតំលៃ

ង- អ្នកធានា ÷ ឈ្មោះ ស្ថានភាពហិរញ្ញវត្ថុ និងមូលនិធិផ្ទាល់សុទ្ធ

### III ព័ត៌មានសំរាប់វាយតំលៃពាក្យសុំឥណទាន

(ព័ត៌មានមួយចំនួនអាចមិនអនុវត្តចំពោះអ្នកសុំខ្ចីដែលជារូបវន្តបុគ្គល)

ក- ការវាយតំលៃ និងអនុសាសន៍របស់មន្ត្រីគ្រប់គ្រងគណនីឥណទាន និងនាយកចាត់ការ

ខ- ការអនុម័ត និងមូលដ្ឋាននៃការអនុម័តដោយគណៈគ្រប់គ្រង ឬគណៈកម្មការឥណទាន

គ- ការវិភាគគុណភាពផ្អែកលើ :

i- ព័ត៌មានរបស់អ្នកសុំខ្ចី

ii- សាវតាស្តីពីទំនាក់ទំនងជាមួយអតិថិជន

iii- ព័ត៌មានស្តីពីទំនាក់ទំនងប្រតិបត្តិការនៃក្រុមពាក់ព័ន្ធផ្សេងទៀតរបស់អ្នកសុំខ្ចីជាមួយធនាគារ

iv- ព័ត៌មានអំពីអ្នកសុំខ្ចីដែលទទួលបានពីគ្រឹះស្ថាននិងប្រភពផ្សេងៗ រួមមានការិយាល័យទំនាក់ទំនងរបស់ធនាគារ

v- ការវិភាគហានិភ័យក្នុងវិស័យ និងអាជីវកម្ម នៃការផ្តល់ឥណទាន

vi- ការប្រមូលផ្តុំឥណទានទៅលើអតិថិជនតែមួយ(បើសមស្រប)

ឃ- ការវិភាគបរិមាណផ្អែកលើៈ

i- ស្ថានភាពហិរញ្ញវត្ថុ និងការអនុវត្តន៍ (គ្រាមុន គ្រាបច្ចុប្បន្ន និងតាមគំរោង)

ii- ផែនការអាជីវកម្ម ប្រភព និងការព្យាករណ៍លំហូរសាច់ប្រាក់សំរាប់បំពេញតំរូវការសងប្រាក់

ង- ប្រភពដើមទុន

ច- កិច្ចសន្យាផ្សេងៗ

ឆ- ការវាយតំលៃនិងតំលៃវត្ថុធានា

## IV ព័ត៌មានសំរាប់ពិនិត្យឥណទានឡើងវិញតាមគ្រា

(ព័ត៌មានមួយចំនួនអាចមិនអនុវត្តចំពោះអ្នកសុំខ្ចីដែលជារូបវន្តបុគ្គល)

ក- ការវាយតំលៃ និងអនុសាសន៍របស់មន្ត្រីពិនិត្យឥណទានឡើងវិញរួមមានៈ

i- ចំណាត់ថ្នាក់ និងកំរិតឥណទានដែលបានយល់ព្រម

ii- សំវិធានធនសំរាប់ការខាតបង់

iii- ការប្រាក់ដែលព្យួរទុក

ខ- ការអនុម័ត និងមូលដ្ឋាននៃការអនុម័តសំរាប់ការផ្តល់ឥណទានជាថ្មី ការកែតំរូវខ្លឹមសារនិងលក្ខខ័ណ្ឌ និងការផ្លាស់ប្តូរចំណាត់ថ្នាក់ឥណទាន ។

គ- ព័ត៌មានដែលអាចទទួលបានចុងក្រោយស្តីពីៈ

i- ឥណទានកំពុងប្រើប្រាស់ រួមមានទ្រព្យអកម្មយថាហេតុ កិច្ចសន្យា និងប្រតិបត្តិការ ក្រៅតារាងតុល្យការដទៃទៀត

ii- ដំណើរការ និងការផ្តល់សេវាកម្មគណនី

iii- ឯកសារទំនាក់ទំនង និងរបាយការណ៍លទ្ធផលនៃការប្រជុំ (call report) ជាមួយអ្នកសុំខ្ចី និងការពិនិត្យដល់ទីកន្លែង

iv- ការវិភាគជាប្រចាំតាមគុណភាពផ្អែកលើព័ត៌មានថ្មីៗបំផុត រួមមានការផ្តល់យោបល់ពីសវនករផ្ទៃក្នុង និងពីខាងក្រៅដែលអាចទទួលបានអំពីអ្នកសុំខ្ចី

ឃ- ការវិភាគចរន្តតាមបែបបរិមាណផ្អែកលើព័ត៌មានហិរញ្ញវត្ថុ ការវាយតំលៃ និងការកំរិតតំលៃថ្មីៗបំផុត

ង- ព័ត៌មានស្តីពីដំណើរការគណនីរបស់ក្រុមដទៃទៀតដែលពាក់ព័ន្ធជាមួយអ្នកសុំខ្ចី ។

ច- វិភាគហានិភ័យក្នុងវិស័យនិងអាជីវកម្មនៃការផ្តល់ឥណទាន